ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

# សេចក្តីបំភ្លឺ
# ស្តីពី
# ការលក់ផ្គត់ផ្គង់ ដឹកជញ្ជូន និងចែកចាយស្បៀងអាហារ និងគ្រឿងឧបភោគបរិភោគចាំបាច់ ដោយក្រសួងពាណិជ្ជកម្ម សម្រាប់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ក្រហម

ដោយមានការផ្តល់មតិយោបល់ជាចំហក្នុងន័យស្ថាបនា ក៏ដូចជាការផ្សព្វផ្សាយព័ត៌មានមិនពិត និងមតិវាយប្រហារបន្ទុចបង្អាក់សកម្មភាពរបស់ក្រសួងពាណិជ្ជកម្ម ព្រមទាំងការបង្ហោះរូបភាពមួយចំនួននៅក្នុងបណ្តាញសង្គម ដែលមានលក្ខណៈបំភ្លៃការពិត និងច្នៃប្រឌិតព័ត៌មានបង្កឲ្យមានការភាន់ច្រលំដល់សាធារណជន បង្កចលាចលក្នុងសង្គម និងធ្វើឲ្យបាត់បង់ទំនុកចិត្តលើការដឹកនាំរបស់រាជរដ្ឋាភិបាលពីសំណាក់មហាជនក្នុងបណ្តាញសង្គម និងពីប្រជាពលរដ្ឋនៅមូលដ្ឋានបិទខ្ទប់បណ្តោះអាសន្នដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលកំពុងជួបប្រទះការលំបាក និងខ្វះខាតស្បៀងអាហារមូលដ្ឋាន ក្រសួងពាណិជ្ជកម្មមានកិត្តិយស សូមឆ្លើយបំភ្លឺជូនសាធារណជនមេត្តាជ្រាបអំពី អាណត្តិ និងការកិច្ចសម្របសម្រួលរបស់ក្រសួងពាណិជ្ជកម្ម ក្នុងការងារលក់ផ្គត់ផ្គង់ ដឹកជញ្ជូន និងចែកចាយលក់ស្បៀងអាហារ និងគ្រឿងឧបភោគបរិភោគចាំបាច់ ជូនប្រជាពលរដ្ឋរស់នៅក្នុងតំបន់ក្រហម ដូចខាងក្រោម៖

## ១. អាណត្តិរបស់ក្រសួងពាណិជ្ជកម្ម

- សេចក្តីណែនាំលេខ ០១ សណន ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការលម្អិតដើម្បីរឹតបន្តឹងការអនុវត្តសេចក្តីសម្រេចស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅ នៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បានប្រគល់ភារកិច្ចឲ្យក្រសួងពាណិជ្ជកម្មលក់ស្បៀងមូលដ្ឋានជាបន្ទាន់ និងសម្របសម្រួលឲ្យមានការផ្គត់ផ្គង់ ដឹកជញ្ជូន និងចែកចាយស្បៀងអាហារ និងគ្រឿងឧបភោគបរិភោគចាំបាច់សម្រាប់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ក្រហម ដោយហេតុថាទីផ្សារ និងទីកន្លែងលក់ម្ហូបអាហារនិងគ្រឿងឧបភោគបរិភោគមួយចំនួន ត្រូវបានផ្អាកសកម្មភាពជាបណ្តោះអាសន្នដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងកំឡុងពេលដែលប្រជាពលរដ្ឋក្នុងតំបន់ក្រហមត្រូវបានហាមឃាត់មិនឲ្យធ្វើដំណើរចេញពីលំនៅដ្ឋាន ឬទីសំណាក់ លើកលែងតែករណីចាំបាច់និងបន្ទាន់មួយចំនួន ដូចមានចែងក្នុងសេចក្តីណែនាំខាងលើ។ ដូច្នេះហើយទើបក្រសួងពាណិជ្ជកម្មបានរៀបចំឲ្យមានការផ្គត់ផ្គង់លក់ស្បៀងតាមរថយន្តចល័ត តាមស្តង់ និងសេវាលក់ស្បៀងមូលដ្ឋានតាមប្រព័ន្ធទូរស័ព្ទ និងលក់តាមទីផ្សារអនឡាញ ហើយដឹកជញ្ជូនចែកចាយដល់មុខផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ក្រហម
- ស្បៀងអាហារ និងគ្រឿងឧបភោគបរិភោគចាំបាច់ជាមូលដ្ឋានដែលលក់ផ្គត់ផ្គង់ដោយក្រសួងពាណិជ្ជកម្មក្នុងតម្លៃទាបជាងទីផ្សារ រួមមាន អង្ករ មី ត្រីខកំប៉ុង ទឹកត្រី ទឹកស៊ីអ៊ីវ ទឹកសុទ្ធ ឆៃប៉ូវ និងស្បៀងមួយចំនួនទៀតដែលដាក់លក់នៅលើទីផ្សារអនឡាញរបស់ក្រសួងពាណិជ្ជកម្ម ដោយផ្តល់សេវាដឹកជញ្ជូនដល់លំនៅដ្ឋានរបស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ក្រហមដោយមិនគិតថ្លៃឈ្នួល ដែលរៀបចំដោយក្រុមការងារក្រសួងពាណិជ្ជកម្មផ្ទាល់ សំដៅចូលរួមអនុវត្តឲ្យបានម៉ឺងម៉ាត់ និងត្រឹមត្រូវបំផុតនូវវិធានការការពារកូវីដ-១៩ កំណត់ដោយក្រសួងសុខាភិបាល
- គិតមកដល់ថ្ងៃនេះ ក្រសួងបានទទួលការបញ្ជាទិញយ៉ាងច្រើនពីប្រជាជន លើទីផ្សារអនឡាញក្រសួងពាណិជ្ជកម្ម ដោយបាននិងកំពុងសម្របសម្រួលបញ្ជូនស្បៀងជូនប្រជាពលរដ្ឋក្នុងតំបន់ក្រហមបានចំនួន ៦០០ ការបញ្ជាទិញ
- ចំពោះប្រជាពលរដ្ឋក្រីក្រដែលកំពុងជួបប្រទះនូវបញ្ហាខ្វះខាតស្បៀងអាហារប្រចាំថ្ងៃចាំបាច់ជាបន្ទាន់ នៅក្នុងកំឡុងពេលនៃការបិទខ្ទប់នេះ ហើយគ្មានលទ្ធភាពទិញស្បៀងដែលលក់ផ្គត់ផ្គង់ដោយក្រសួងពាណិជ្ជកម្ម និងលក់ដោយ

ឡូតិ៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ៖ (៨៥៥) ២៣ ៨៦៦ ៤៦៩
Lot 19-61 Russian Federation Blvd., Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Fax: (855) 23 866 469

អាជីវករឯកជន ប្រជាពលរដ្ឋក្រីក្រទាំងនោះអាចជូនដំណឹងទៅគណៈកម្មការជាតិគ្រប់គ្រង និងដឹកនាំការអនុវត្តវិធានការបិទខ្ទប់ ដែលហៅកាត់ថា "គ.ប.ខ." តាមរយៈក្រុមតេឡេក្រាម (Group Telegram) "តម្រូវការបន្ទាន់នូវជំនួយស្បៀងចាំបាច់ (គ.ប.ខ.)" ដោយបញ្ជាក់ឲ្យបានច្បាស់លាស់អំពី៖ (១) ស្ថានភាពមុខរបរ (២) ស្ថានភាពគ្រួសារ (៣) ស្ថានភាពបន្ទាន់ចាំបាច់ដែលមានតម្រូវការស្បៀង (៤) ទីតាំងស្នាក់នៅ ដូចជា លេខផ្ទះ លេខផ្លូវ សង្កាត់ ខណ្ឌ និង (៥) លេខទំនាក់ទំនង ដើម្បីទទួលបាននូវស្បៀងជំនួយសង្គម។ បន្ទាប់មក គណៈកម្មការ គ.ប.ខ. នឹងរៀបចំចាត់ចែងជូនតាមសំណូមពរជាបន្ទាន់ និងតាមការចាំបាច់។

## ២. **ភារកិច្ចរបស់ក្រសួងពាណិជ្ជកម្ម**

- ជាមួយនឹងការលក់ផ្គត់ផ្គង់ស្បៀង និងគ្រឿងឧបភោគបរិភោគចាំបាច់សម្រាប់ប្រជាពលរដ្ឋនៅក្នុងតំបន់ក្រហម ដូចបានបញ្ជាក់ខាងលើ ក្រសួងពាណិជ្ជកម្មក៏បានបញ្ចេញស្បៀងឲ្យចរាចរណ៍ក្នុងទីផ្សារតាមរយៈរថយន្តចល័តរបស់ក្រុមហ៊ុនហ្គ្រីនត្រេដ និងរបស់ក្រសួងចំនួន៨គ្រឿង និងបើកស្តង់លក់ទំនិញរបស់ក្រសួងពាណិជ្ជកម្ម សរុបមាន១១ទីតាំង ដែលមាន ២៥ស្តង់ ដើម្បីទ្រទ្រង់ស្ថិរភាពថ្លៃទំនិញជាស្បៀងមូលដ្ឋាន ក៏ដូចជាទប់ស្កាត់ការឡើងថ្លៃហួសហេតុដែលបង្កឡើងដោយជនឆក់ឱកាស និងជនខិលខូចមួយចំនួន។ ក្រសួងពាណិជ្ជកម្មក៏បានចាត់មន្ត្រីរបស់ខ្លួនឲ្យបន្តចុះត្រួតពិនិត្យ និងតាមដានសន្ទស្សន៍ថ្លៃទំនិញតាមទីផ្សារជាប្រចាំ ដើម្បីទប់ស្កាត់ការបន្លំគុណភាព ការលក់ដូរបំប៉ោងតម្លៃទំនិញ ព្រមទាំងណែនាំដល់អាជីវករទាំងអស់ឲ្យបិទស្លាកថ្លៃនៅលើមុខទំនិញ និងកុំឲ្យមានការផ្លាស់ប្តូរថ្លៃទំនិញតាមអំពើចិត្តលើសពីតម្លៃទំនិញដែលបានលក់មុនពេលបិទខ្ទប់។ ក្នុងករណីមានការលួចបន្លំដំឡើងថ្លៃណាមួយកើតឡើង ប្រជាពលរដ្ឋអាចរាយការណ៍ជាបន្ទាន់មកកាន់អាជ្ញាធរមានសមត្ថកិច្ច និងអង្គភាពពាក់ព័ន្ធរបស់ក្រសួង ឬមន្ត្រីប្រចាំការនៅតាមស្តង់លក់ទំនិញ ដើម្បីចាត់វិធានការឲ្យបានទាន់ពេលវេលា។

## ៣. **ការសម្របសម្រួលរបស់ក្រសួងពាណិជ្ជកម្ម**

- ដើម្បីបម្រើតម្រូវការទំនិញជាស្បៀង និងគ្រឿងឧបភោគបរិភោគដទៃទៀតក្រៅពីស្បៀងដែលក្រសួងលក់ផ្គត់ផ្គង់ ក្រសួងពាណិជ្ជកម្មបានសម្របសម្រួលជាមួយក្រុមហ៊ុនឯកជន និងអាជីវករមួយចំនួន ដើម្បីចូលរួមផ្គត់ផ្គង់ទំនិញចាំបាច់ដទៃទៀតជូនដល់ប្រជាពលរដ្ឋ។ តាមរយៈការសម្របសម្រួលនេះ ក្រសួងពាណិជ្ជកម្មបានតម្រូវឲ្យមានការលក់តែទំនិញដែលមានតម្រូវការចាំបាច់បំផុតដូចជា មាន់ ត្រី សាច់ បន្លែ ផ្លែឈើ អាហារសម្រាប់កុមារ និងម្ហូបក្រៀមផ្សេងៗក្នុងតម្លៃសមស្រប និងតម្រូវឲ្យការលក់មានរបៀបរៀបរយតាមវិធានការការពាររបស់សុខាភិបាល
- បន្ទាប់ពីមានវិធានការដាក់ចេញជាបន្តបន្ទាប់ដោយរាជរដ្ឋាភិបាលសំដៅការពារការឆ្លងរាលដាលជំងឺកូវីដ-១៩ ជាពិសេសការផ្អាកជាបណ្តោះអាសន្ននូវទីផ្សាររដ្ឋ និងផ្សារមិនរៀបរយទាំងអស់ ក្នុងរាជធានីភ្នំពេញ ក៏មានការលើកឡើងជាមតិចំហក្នុងបណ្តាញសង្គមមួយចំនួនថា ក្រសួងពាណិជ្ជកម្មគួរអនុញ្ញាតឲ្យប្រជាពលរដ្ឋនិងអាជីវករ ចូលរួមលក់ទំនិញតាមទីតាំងរបស់ក្រសួងពាណិជ្ជកម្មដែលបង្កើតឡើងក្នុងទ្រង់ទ្រាយតូចៗ ដែលប្រការនេះគឺផ្ទុយទាំងស្រុងទៅនឹងវិធានការការពាររបស់រាជរដ្ឋាភិបាល ដែលបានហាមប្រាមការប្រមូលផ្តុំមនុស្សច្រើន ហើយវាមានន័យស្មើគ្នានឹងការអនុញ្ញាតឲ្យបង្កើតផ្សារសាជាថ្មីឡើងវិញ ដែលអាចជាប្រភពនៃការចម្លងខ្ពស់ ឬបង្កើនការរីករាលដាលនៃជំងឺកូវីដ-១៩ ទៀតផង។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

សម្រាប់ព័ត៌មានបន្ថែម ឬសំណូមពរផ្សេងៗទាក់ទងនឹងតួនាទីឬសកម្មភាពរបស់ក្រសួងពាណិជ្ជកម្ម សូមទាក់ទងមកការិយាល័យអ្នកនាំពាក្យក្រសួងពាណិជ្ជកម្ម ដែលមានទូរស័ព្ទដូចខាងក្រោម៖

- ឯកឧត្តម **ស៊ាង ថៃ** រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងពាណិជ្ជកម្ម៖ 012313333
- ឯកឧត្តម **ប៉ែន សុវិជាតិ** អនុរដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងពាណិជ្ជកម្មឆ្លាស់វេន៖ 012816663

ថ្ងៃអង្គារ ១រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១

ក្រសួងពាណិជ្ជកម្ម

ឡូតិ៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ៖ (៨៥៥) ២៣ ៨៦៦ ៤៦៩
Lot 19-61 Russian Federation Blvd., Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Fax: (855) 23 866 469